ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

# បទអន្តរាគមន៍
# ក្នុងសិក្ខាសាលាស្តីពីការពង្រឹងការអនុវត្តច្បាប់ ដើម្បីយុត្តិធម៌ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ដោយឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច
អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអនុប្រធាន គ.ជ.ប.ជ

សណ្ឋាគារអាំងទ័រកុងទីណង់តាល់, ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦

**សូមគោរព**

- សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ (ឯកឧត្តមអគ្គស្នងការនគរបាលជាតិ)
- ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី
- ភ្ញៀវជាតិ អន្តរជាតិជាទីរាប់អាន

ថ្ងៃនេះ ក្នុងនាមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខ្ញុំពិតជាមានសេចក្តីរីករាយដែលមានឱកាសបានចែករំលែកអំពីលទ្ធផលការងារពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ដើម្បីយុត្តិធម៌ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងទិដ្ឋភាពច្បាប់ផ្សេងៗ ដែលក្រសួងបានបំពេញក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីជួយជនរងគ្រោះដោយអំពើជួញដូរ។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គ ដោះស្រាយរាល់បញ្ហា និងការលំបាកគ្រប់បែបយ៉ាង ដើម្បីប្រជាជនកម្ពុជា និងមនុស្សគ្រប់រូប ឱ្យទទួលបាននូវការគោរពសិទ្ធិ សេចក្តីថ្លៃថ្នូរ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ព្រមទាំងបង្កើនការពង្រឹងអនុវត្តច្បាប់ អនុសញ្ញា កតិកាសញ្ញាអន្តរជាតិ ច្បាប់ជាតិ និងកិច្ចព្រមព្រៀងទ្វេភាគី-ពហុភាគី និងផែនការសកម្មភាពជាតិ និងបទដ្ឋានគតិយុត្តអនុស្សរណៈ ទាំងឡាយ ឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ស្របតាមស្ថានភាពជាក់ស្តែង របស់កម្ពុជា។

ផ្តើមចេញពីកិច្ចការខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ជាសេនាធិការ ក្នុងការបំពេញការងារជួយជនរងគ្រោះ ដោយផ្អែកតាមកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងទទួលបានលទ្ធផលដូចខាងក្រោម៖

- បានសហការជាមួយនឹងសាលាដំបូងរាជធានីភ្នំពេញ ជួយសម្របសម្រួលសាក្សី និងជនរងគ្រោះ **ចំនួន ៤៩នាក់** ក្នុង **២២ សំណុំរឿង**
- បានសហការជាមួយដៃគូ ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ និងកេងប្រវ័ញ្ចកំលាំងពលកម្ម សរុបចំនួន **២២៦នាក់**

- បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងវៀតណាម **ចំនួន ២០២ នាក់**
- បានទទួលជនរងគ្រោះដោយសារអំពើជួញដូរដែលនិរទេសពីប្រទេសវៀតណាម**ចំនួន ១០៩ នាក់**
- បានធ្វើសមាហរណកម្ម និងប៉ាន់ប្រមាណគ្រួសារដោយអំពើជួញដូរមនុស្សលោភបំពានផ្លូវភេទ និងកេងប្រវ័ញ្ចពលកម្មទៅសហគមន៍វិញ សរុបចំនួន **៤៣ នាក់** និងបានបិទសំណុំរឿងសរុប **ចំនួន ១៦ ករណី**
- បាននិងកំពុងសហការជាមួយភាគីថៃ រៀបចំសាងសង់មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធានាការទទួលជនរងគ្រោះ ជនងាយរងគ្រោះ និងពលករខុសច្បាប់ដែលភាគីថៃបានបញ្ជូនមក
- បានរៀបចំគោលនយោបាយ និងបទដ្ឋានអប្បបរមាស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- បានរៀបចំបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលជាដើម។

ផ្អែកតាមការអនុវត្តជាក់ស្ដែង យើងមានលិខិតបទដ្ឋានជាច្រើនសម្រាប់ជួយជនរងគ្រោះដូចជា៖

- ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស
- ច្បាប់ស្ដីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន
- គោលនយោបាយ និងបទដ្ឋានអប្បបរមាស្ដីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- បទដ្ឋានអប្បបរមា ស្ដីពីការថែទាំជំនួសចំពោះកុមារ និងបទដ្ឋានការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅមជ្ឈមណ្ឌល។ល។
- រៀបចំជនបង្គោលគ្រប់រាជធានី ខេត្តក្រុង ស្រុកដែលជាយន្តការសម្រាប់ទំនាក់ទំនងស្រាវជ្រាវរកគ្រួសារជនរងគ្រោះ។

ទោះបីជាយ៉ាងនេះក្ដី ក៏យើងនៅជួបបញ្ហាប្រឈមមួយចំនួនដូចជា៖

- មិនទាន់មានមជ្ឈមណ្ឌលរដ្ឋសម្រាប់ស្ដារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅឡើយ
- មជ្ឈមណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ពុំទាន់មានសម្បទាគ្រប់គ្រាន់ក្នុងការគ្រប់គ្រងជនរងគ្រោះឱ្យស្នាក់នៅ

- រដ្ឋបាលឃុំ សង្កាត់ភាគច្រើន មិនបានប្រើប្រាស់មូលនិធិសម្រាប់ជួយដល់ជនរងគ្រោះ និងងាយរងគ្រោះនៅមូលដ្ឋានរបស់ខ្លួនទេ មូលនិធិភាគច្រើនចំណាយតែលើការកសាងហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះ
- កញ្ចប់ថវិកាគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ នៅមានកម្រិតនៅឡើយ
- ការស្រាវជ្រាវរកគ្រួសាររបស់អតិថិជនមានការលំបាក
- ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារការជួញដូរមនុស្សមកពីប្រទេសថៃ មានការផ្តល់ព័ត៌មានយឺតយ៉ាវ
- ជនរងគ្រោះមិនមានទំនុកចិត្ត និងយល់អំពីប្រព័ន្ធយុត្តិធម៌
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ចៅក្រម ចៅក្រមស៊ើប និងក្រឡាបញ្ជីមួយចំនួនពុំទាន់ស្គាល់ និងយល់អំពីប្រព័ន្ធការងារ តួនាទីភារកិច្ចរបស់អ្នកសម្របសម្រួលសាក្សី និងជនរងគ្រោះ និងពុំទាន់សហការពេញលេញ
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ចៅក្រម ចៅក្រមស៊ើប និងក្រឡាបញ្ជីមួយចំនួនពុំទាន់ទទួលស្គាល់ពីសារៈសំខាន់នៃគម្រោងអ្នកសម្របសម្រួលសាក្សីជនរងគ្រោះ នៅក្នុងប្រព័ន្ធយុត្តិធម៌។

ដើម្បីធានាដល់ការពង្រឹងយន្តការដែលមានស្រាប់ ក្រសួង ស.អ.យ បានដាក់ចេញនូវទិសដៅចំពោះមុខរួមមាន៖

- បន្តការផ្សព្វផ្សាយ គោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- បន្តសហការជាមួយនឹងប្រទេសដែលបានចុះអនុស្សារណៈ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បន្តពង្រឹងអនុវត្តកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការធ្វើសមាហរណកម្មជនរងគ្រោះទៅគ្រួសារ និងសហគមន៍
- បង្កើនការទំនាក់ទំនងផ្ទាល់ជាមួយមន្ត្រីសង្គមកិច្ចរាជធានី ខេត្ត ក្នុងការស្រាវជ្រាវប៉ាន់ប្រមាណគ្រួសារ
- បង្កើនកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

អាស្រ័យហេតុនេះ ខ្ញុំសង្ឃឹមថា អង្គសិក្ខាសាលាទាំងមូលនឹងលើកយកទស្សនវិស័យវែងឆ្ងាយ សម្រាប់ជាមូលដ្ឋានពិភាក្សា ដើម្បីរិះរកចំណុចគន្លឹះក្នុងការចាត់វិធានការលើករណីនីមួយៗប្រកបដោយប្រសិទ្ធភាព និងធានាកាត់បន្ថយការរំលោភបំពាន ការជួញដូរមនុស្ស និងកិច្ចការផ្សេងៗទៀតដែលអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស និយាយជារួម។

ដោយឡែក យើងទាំងអស់គ្នានឹងខិតខំពង្រឹងយន្តការដែលមានស្រាប់ ឱ្យធានាបានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ពិសេសជាងនេះទៀតគឺខិតខំពិនិត្យមើលចំណុចសេសសល់ ដែលទាមទារបន្ថែមលើយន្តការដែលមានស្រាប់ ឬបង្កើតនូវលិខិតបទដ្ឋានចាំបាច់សំដៅជួយដល់ជនរងគ្រោះ។

ជាថ្មីម្តងទៀត ក្នុងនាមក្រសួង ស.អ.យ ខ្ញុំសូមថ្លែងអំណរគុណដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងមហាផ្ទៃ ដែលបានរៀបចំសិក្ខាសាលានេះឡើង ក្នុងគោលបំណងរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស និងបង្កើនការទប់ស្កាត់ឱ្យកាន់តែខ្លាំងក្លាថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរពរដល់ សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកា នៃអង្គសិក្ខាសាលាទាំងមូល ទទួលបាននូវសុខភាពល្អ ថាមពលមាំមួន និងជោគជ័យថ្មីៗបន្ថែមទៀត។

**សូមអរគុណ** !